ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ៤៦៧ **តុលាការកំពូល**

ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៣

*សាលដីកា* បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា

លេខ : ២៩៣ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម-របាយការណ៍

៤- លោក ស៊ិន ឌីម ជាចៅក្រម

៥- លោក យូរ ឧត្តរា ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទឈ្មោះម៉ាហ្គាំង អ៊ែសណែស (ជាចុងបណ្តឹងសាទុក្ខ) អាយុ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅផ្ទះលេខ១៦៤$E_{22}$ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយលោកមេធាវីការ សាវ័ត្ថ ជាតំណាង ។

-ដើមចោទឈ្មោះល័ក្ខ សុខធីណា (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ០២៥H ផ្លូវដើមខិត ក្រុម១៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរជាអនុប្រធានសមាគមន៍ និង ជាប្រធានផ្នែកអភិវឌ្ឍន៍ នៃពុទ្ធសាសនា សង្គ្រោះជនក្រីក្រ ។

-មានមេធាវីលោកអិន ហ៊ីង ជាតំណាង

-ចុងចម្លើយឈ្មោះច្រឹង លីមស៊្រី (ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ គ្រូបង្រៀន ទីលំនៅផ្ទះលេខ៣៩៤ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ និង ប្រពន្ធឈ្មោះ

ថៅ វ៉ាន់នី ហៅណា វ៉ាន់នី អាយុ៤៤ឆ្នាំ ជាតិខ្មែរ ។

មានមេធាវីលោកឈី សម្បត្តិ

*កម្មវត្ថុ* : សុំបដិសេធប័ណ្ណលក់ដីពីឈ្មោះថៅ វ៉ាន់នី ហៅឈ្មោះណា វ៉ាន់នី ទៅអោយឈ្មោះអ៊ីង ជុងកេង និង ឈ្មោះគង់ ទិតធា ចោល ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣១៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣របស់ឈ្មោះច្រឹង លឹមស្រ៊ី ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៦៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣របស់តុលាការកំពូល។

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០ របស់ដើមចោទលោកម៉ា ឃ្លាំងអ៊ែសណែសថា : ខ្លួនប្តឹងសុំបដិសេធប័ណ្ណលក់ដីពីឈ្មោះថៅ វ៉ាន់នី ទៅអោយឈ្មោះអ៊ីង ជុងកេង និង គង់ ទិតធា ចោល និង សុំទិញដីតាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៦ បើពុំបានទិញដីសុំប្តឹងទាមទារប្រាក់ចំនួន៦០.០០០$ ដែលបានផ្តល់អោយចុងចម្លើយរួចកន្លងមក សុំទាមទារប្រាក់ជំងឺចិត្ត និង ការខូចខាតចំនួន១០០.០០០$ និង សុំដាក់គុកបង្ខំរូបកាយ ។ ដោយមូលហេតុថា ចុងចម្លើយ ថៅ វ៉ាន់នី ប្តីឈ្មោះច្រឹង លឹមស្រ៊ី ដែលជាភាគី"ក" ក្នុងកិច្ចសន្យាលក់ទិញដី និង ខ្លួនជាភាគី"ខ" បានសន្យាផ្ទាល់មាត់ជាមួយខ្លួនថា ចុងចម្លើយ និង ធ្វើប្លង់ព្រមទាំងប័ណ្ណកម្មសិទ្ធិដីអោយ ប្រសិនបើខ្លួនសុខចិត្តទិញដីរបស់គាត់ ។ ចុងចម្លើយបានឆបោកខ្លួនលើកទី១ ដោយចុងចម្លើយគ្រាន់តែធ្វើកិច្ចសន្យា ដើម្បីធ្វើផ្លាក់ក្នុងការទទួលយកលុយពីខ្លួនអោយដល់ដៃចុងចម្លើយតែប៉ុណ្ណោះ ដោយបំភ័ន្តលើកិច្ចសន្យាទុកចិត្តថា ចុងចម្លើយបានលក់ដីអោយខ្លួនហើយ ។ ដោយមានការភ័ន្តច្រឡំ និង មានការទុកចិត្តខ្លួនក៏បានប្រគល់ប្រាក់អោយថ្លៃដីទៅចុងចម្លើយមួយចំនួនភ្លាម ព្រោះសំអាងលើប្រាក់ដែលខ្លួនអោយទៅ មានកិច្ចសន្យាទិញលក់ដីពិតប្រាកដធ្វើនៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៩៦ ព្រមទាំងមានចែងក្នុងប្រការនីមួយៗ ដែលភាគីចុងចម្លើយ( ភាគី គ) មានគំរោងទុកជាមុនហើយស្រេចក្នុងប្រការទាំងនោះ ដើម្បីបន្លំខ្លួន ។ ក្រោយពេលខ្លួនប្រគល់លុយត្រង់ចំណុចប្រការ២ និង ប្រការ៣ នៅក្នុងកិច្ចសន្យារួច ទើបចុងចម្លើយយកប្លង់ដីដែលខ្វះសេចក្តីសំរេចពីសាលាក្រុងមកទុកអោយខ្លួន ហើយចុងចម្លើយអោយភាគីខ្លួនថែមលុយចំនួន៨.០០០$ នៅក្រៅកិច្ចសន្យាថា យកទៅបង់ពន្ធអោយថ្លៃផ្ទេរសិទ្ធិអោយខ្លួន ។ ខ្លួនទុកចិត្តក៏បានប្រគល់ប្រាក់បន្ថែមនេះទៅអោយចុង-ចម្លើយ មួយរយៈធំក៏មិនឃើញចុងចម្លើយមកធ្វើការផ្ទេរកម្មសិទ្ធិដី ខ្លួនបានទៅសួររកកម្មសិទ្ធិដីពីចុង-ចម្លើយ ភាគីចុងចម្លើយបានភូតភរខ្លួនពី១ខែ ទៅ១ខែ រហូតទាស់តែជិតដល់ពេលកំណត់ខសន្យារបស់ខ្លួន ចុងចម្លើយយកឡេះថា ក្រុងមិនចេញប័ណ្ណកម្មសិទ្ធិអោយទេ ទាល់តែអ្នកទិញធ្វើអភិវឌ្ឍន៍ទើបក្រុងចេញប័ណ្ណដីអោយប្រើប្រាស់។ ពេលនោះភាគីចុងចម្លើយបានបបួលខ្លួនធ្វើអភិវឌ្ឍចូលគ្នា ព្រោះដីធ្វើកម្មសិទ្ធិមិនបានទាល់តែធ្វើអភិវឌ្ឍន៍ទាំងអស់គ្នា ទើបធ្វើប័ណ្ណកម្មសិទ្ធិដីបាន ខ្លួនក៏សុខចិត្តរួមសហការគ្នាធ្វើអភិវឌ្ឍន៍ទៀត ដោយភាគីចុងចម្លើយសន្យាផ្ទាល់មាត់ដែរថា អោយខ្លួនធ្វើជាអនុប្រធាន ខ្លួនឮដូច្នេះក៏ជឿទុកចិត្ត។

ភាគីចុងចម្លើយបើកក្រុមហ៊ុនមួយឈ្មោះអភិវឌ្ឍន៍សង្គម ក៏បានរៀបចំល័ក្ខន្តិកៈក្រុមហ៊ុន ដោយដាក់ឈ្មោះខ្លួនធ្វើជាអនុប្រធានមែន តែដល់ច្បាប់លក្ខន្តិកៈសំរេចចេញពីក្រសួងពាណិជ្ជកម្មមកវិញ ស្រាប់តែឃើញមានឈ្មោះលឿង ផន ជាអនុប្រធានទៅវិញ ឯខ្លួនគ្មានឈ្មោះសោះ ។ ពេលនោះខ្លួនក៏បានអង្វរភាគីចុងចម្លើយអោយបញ្ចូលឈ្មោះខ្លួនតាមពាក្យសន្យារបស់ចុងចម្លើយ ។ លុះក្រោយមកសមាសភាពខាងភាគីខ្លួនដែលនៅក្នុងសមាគម ក៏បានដកយកលិខិតឈ្មោះលឿង ផន ចេញពីក្រសួងពាណិជ្ជកម្ម ដើម្បីប្តឹងរំលាយច្បាប់ក្រុមហ៊ុនចោល ពេលនោះប្រធានក្រុមហ៊ុន គឺចុងចម្លើយ ( ណា វ៉ាន់នី ) ក៏បានសំរួលលប់ឈ្មោះលឿង ផន ចេញពីអនុប្រធានក្រុមហ៊ុនអភិវឌ្ឍន៍សង្គម ដោយខ្លាចមានរឿង ។ ក្រោយពេលលប់ឈ្មោះលឿង ផន ចុងចម្លើយក៏ទៅដូរឈ្មោះក្រុមហ៊ុន កែដាក់ថា ក្រុមហ៊ុនខ្មែរអភិវឌ្ឍន៍សង្គមវិញ ដោយបានដាក់ឈ្មោះស្លាប នាយូរ ជាអនុប្រធានក្រុមហ៊ុន ដោយលួចលាក់ពីសមាសភាពក្រុមហ៊ុន ។ ឃើញដូច្នេះ សមាសភាពរបស់ភាគីខ្លួន ក៏បានធ្វើពាក្យបណ្តឹងមួយច្បាប់ដាក់ជូនសាលាក្រុង អំពីការឈប់សហការណ៍អភិវឌ្ឍន៍ជាមួយក្រុមហ៊ុនបោកប្រាស់ ។ ចំណែកដីជាង៤០ហិកតារបស់ភាគីខ្លួនដោយសារការឈប់សហការណ៍ ក៏ត្រូវខូចខាតប្រាក់កក់ថ្លៃដីអស់រាប់ម៉ឺនដុល្លា ។ ដូច្នេះភាគីខ្លួនរងគ្រោះក្នុងការខាតបង់រឿងក្រុមហ៊ុនជារឿងមួយផ្សេងរវាងភាគីខ្លួន និង ភាគីចុងចម្លើយ ។ល។ រឿងប្រាក់ជាង៥០.០០០$ ដែលភាគីខ្លួនប្រគល់អោយភាគីចុងចម្លើយនៅពេលហួស ខ សន្យាក្នុងប្រការ៤ ភាគីចុងចម្លើយមិនអើពើចំពោះរឿងប័ណ្ណដី ដែលត្រូវប្រគល់អោយភាគីខាងខ្លួនឡើយ ។ ពេលមានល្បិចក្បត់ក្នុងកិច្ចសន្យាលក់ដីរបស់ភាគីចុងចម្លើយ ទើបភាគីខ្លួនមិនប្រគល់ប្រាក់អោយភាគីចុងចម្លើយក្នុងប្រការ៤ នៃកិច្ចសន្យានោះឡើយ រង់ចាំខ្លួនបានទទួលប័ណ្ណកម្មសិទ្ធិដីផ្ទេរបានពីភាគីចុងចម្លើយសិន ។ ចុងចម្លើយបានបោកប្រាស់ភាគីខ្លួន ដោយលក់ដីអោយទៅអ្នកផ្សេង ហើយថែមទាំងមិនប្រគល់លុយថ្លៃកក់ដីរបស់ភាគីខ្លួនវិញទេ ។ ខ្លួនសំណូមពរដូចតទៅ :

-សុំអោយមានវិធានការណ៍ជាកិច្ចការប្រញាប់ ដើម្បីខ្ទប់រាល់ការសាងសង់ផ្សេងៗនៅលើដីជាប់កិច្ចសន្យាលក់-ទិញ ។

-សុំកុំអោយភាគីចុងចំលើយលក់ដីដែលជាប់កិច្ចសន្យាជាមួយខ្លួនអោយភាគីផ្សេងដែលបានធ្វើប័ណ្ណកម្មសិទ្ធិរួចក្រោយពាក្យបណ្តឹងរបស់ខ្លួន ។

-សុំអោយចុងចំលើយប្រគល់សិទ្ធិដី ដោយផ្ទេរសិទ្ធិអោយមកភាគីខ្លួន ដោយដាក់ឈ្មោះម៉ា ហ្គាំងអ៊ែរណែស ដើម្បីបានប្រគល់ប្រាក់ថ្លៃទិញដីអោយគ្រប់ចំនួនដូចតាមកិច្ចសន្យា ។

-ទាមទារអោយចុងចំលើយ ថៅ វណ្ណនី សងជំងឺចិត្ត និង ការប្រាក់ចំនួន១០០.០០០$ ។

-បានឃើញដីកាតម្កល់ និង ចំណាយរឿងលេខ៨១៧៤ ត-រ/២០០០ចុះថ្ងៃទី១៤ ខែធ្នូឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-តម្កល់សំណុំរឿងរដ្ឋប្បវេណីលេខក្តី៦៥៧/០១-០៨-២០០០ ទុកមួយអន្ទើ ហើយបង្គាប់អោយចំណាយរឿងចេញពីបញ្ជីចាប់ពីពេលនេះតទៅ ។

២-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន៧.០០០រៀល ដែលដើមចោទបានបង់ដាក់ថវិការដ្ឋ និង ចំណាយផ្សេងៗរួចហើយ ។

៣-ដីកាសំរេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាម១ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៦"ក" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះម៉ាហ្គាំង-អ៊ែរណែស ប្ដឹងមិនសុខចិត្តពីដីកាតម្កល់ និង ចំណាយរឿងលេខ៨១៧៤ ត-រ/២០០០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៨"ង" ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះម៉ាហ្គាំង អ៊ែរណែស ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធដីកាតំកល់រឿងទុកមិនចាត់ការ និង ចំណាយរឿងរដ្ឋប្បវេណីលេខ៦៥៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ ចេញពីបញ្ជីក្ដីលេខ៨១៧៤ ត.រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៣-ទទួលស្គាល់កិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៦ រវាងឈ្មោះណា វ៉ាន់នី ប្ដីឈ្មោះច្រឹង លឹមស្រ៊ី និង ឈ្មោះម៉ាហ្គាំង អ៊ែរណែស ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បដិសេធការផ្ទេរកម្មសិទ្ធិលើដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៥៧៣ ចុះថ្ងៃទី០៤ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់នាយកដ្ឋានសុរិយោដី ពីឈ្មោះថោ វ៉ាន់នី ទៅអោយឈ្មោះអ៊ឹង ដុងកេង និង ឈ្មោះម៉ាក់ សុម៉ាលី តាមសំបុត្រលក់ផ្ដាច់ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៨ ។

៥-បង្គាប់អោយសមាគមពុទ្ធសាសនាសង្គ្រោះជនក្រីក្រដែលមានឈ្មោះល័ក្ខ សុខធីណា ជាតំណាងបង់ប្រាក់បង្គ្រប់ថ្លៃដីចំនួន៥.៧០០០ដុល្លាអាមេរិក (ប្រាំម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិក) អោយទៅឈ្មោះថោ វ៉ាន់នី និង ប្ដីឈ្មោះច្រឹង លឹមស្រ៊ី និងប្រគល់ដីទំហំ០១ហិកតា៧១អា១៣សង្ទីអា ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវចោមចៅ ខាងត្បូងទល់ដីគង់ទិតធា ខាងកើតទល់ស្ថានីយវិទ្យុស្ទឹងមានជ័យ ខាងលិចទល់ដីសុខ អ៊ាម ស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ អោយទៅសមាគមពុទ្ធសាសនាសង្គ្រោះជនក្រីក្រជាកម្មសិទ្ធិ ចាប់ពីពេលសាលដីកានេះចូលជាស្ថាពរ ។

៦-បង្គាប់អោយចុងចំលើយសងសោហ៊ុយបង់ខាតជំងឺចិត្តចំនួន១០.០០០ដុល្លាអាមេរិក (មួយម៉ឺនដុល្លាអាមេរិក) ទៅអោយដើមចោទ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៧-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍១៣.០០០រៀល ដែលដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្ទឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០រៀល និង អាជ្ញាធរតុលាការចំនួន៥.០០០រៀល សរុប ១៣.០០០រៀល ។ កាលបើសាលដីកានេះចូលជាស្ថាពរបង្គាប់អោយចុងចំលើយសងប្រាក់១៣.០០០រៀល

អោយទៅដើមចោទវិញ និង បង្គាប់អោយចុងចំលើយបង់ពន្ធសមាមាត្រ១% លើតំលៃដីទំនាស់ និង លើប្រាក់សំណងជំងឺចិត្ត ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង មេធាវីដើមចោទ កំបាំងមុខចុងចំលើយ ។ បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ៥៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះច្រឹង លឹមស៊្រុំ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៤៨"ង" ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣របស់ឈ្មោះច្រឹង លឹមស្រ៊ុ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៤៨"ង" ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ មេធាវីការពារដើមចោទ កំបាំងមុខចុងចំលើយ និង មេធាវីការពារចុងចំលើយ តែចាត់ទុកជាចំពោះមុខ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣១៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣របស់ឈ្មោះច្រឹង លឹមស្រ៊ុ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះច្រឹង លឹមស្រ៊ុ ។

-បានឃើញសារណាតប ចុះថ្ងៃទី.........ខែ.............. ឆ្នាំ........ របស់ឈ្មោះល័ក្ខ សុខធីណា ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ នៅពេលសវនាការថា : សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

-បានស្តាប់ចំលើយរបស់លោកច្រឹង លឹមស្រ៊ុ ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការបានលើកឡើងថា : នៅឆ្នាំ១៩៩០ ខ្លួនបានទិញដីពីប្រជាជន៣គ្រួសារ មានតែចុងសន្ទឹកមិនទាន់មានប្លង់រឹងទេ ។ ក្រោយមកនៅឆ្នាំ១៩៩៦ លោកម៉ាហ្គាំ អែលណែស គាត់បានមកទំនាក់ទំនងចង់ទិញដីរបស់ខ្លួន ខ្លួនក៏បានបង្ហាញដីដែលគាត់ចង់បាន គាត់ចង់បានដីនោះដើម្បីធ្វើជាប្លង់រឹង គាត់ក៏បានទាក់ទងពីសង្កាត់ ខ័ណ្ឌ ក្រុង ដើម្បីចេញជាប្លង់រឹង ។ លោកម៉ាហ្គាំង អែលណែស គាត់គ្មានប្រាក់ទេ គាត់ចាំប្រាក់

ដែលក្មួយគាត់ផ្ញើរមកអោយគាត់ ខ្លួនបានធ្វើកិច្ចសន្យាជាមួយគាត់ថា អ៊ុំឯងត្រូវប្រគល់ប្រាក់១ម៉ឺនដុល្លាទៀតឱ្យខ្លួនរត់ការឱ្យ គាត់ក៏មើលកិច្ចសន្យា គាត់ក៏យល់ព្រម ។ ក្រោយមកក៏បាត់គាត់រហូត លុយមួយម៉ឺនដុល្លារត់ការបង្គ្រប់ឱ្យខ្លួនក៏គ្មាន ហើយបានបាត់គាត់តាំងពីថ្ងៃហ្នឹងមក ។ បន្ទាប់មកទៀតខ្លួនបានរត់ចេញជាប្លង់រឹងបាន ខ្លួនក៏លក់ឱ្យអ្នកផ្សេងទៀត ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកការ សាវុត្ថ ជាមេធាវីតំណាងឱ្យលោកម៉ាហ្គ្រាំង អ៊ែលណៃស ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការ ថា : នៅក្នុងប្រការ៥ នៃកិច្ចសន្យា ភាគីអ្នកលក់ដីបានទទួលស្គាល់៤.៤០០០ដុល្លាអាមេរិក រួចហើយ មានន័យថា អ្នកលក់បានរត់ការឱ្យកូនក្តីខ្លួនហើយ ។ ចំនុចមួយទៀតឃើញថា អ្នកលក់បានទទួលលុយ១.៩០០០ដុល្លាអាមេរិកហើយ ខ្លួនសូមតម្កល់សាលដីកាសាលា-ឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកអ៊ិន ហ៊ីង ជាមេធាវីតំណាងឱ្យអ្នកស្រីល័ក្ខ សុខធីណា ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : ប្រពន្ធរបស់លោកច្រឹង លឹមស្រ៊ី ឈ្មោះណា វ៉ាន់នី គាត់បានមកអញ្ជើញអ្នកស្រីល័ក្ខ សុធីណា ទៅពិភាក្សា គាត់បានទទួលលុយរួចហើយ ១៩.០០០ដុល្លាអាមេរិក កំហុសទាំងនេះមិនមែនជាកំហុសរបស់កូនក្តីខ្លួនទេ ។ ហេតុផលដែល ច្រឹង លឹមស្រ៊ី គាត់រត់ការខ្លួនឯងទេ ហើយគាត់ថា លុយនេះជាលុយគាត់ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈី សម្បត្តិ ជាមេធាវីការពារអោយលោកច្រឹង លឹមស្រ៊ី ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ថា : ចំពោះសាលក្រមលេខ៥០"ឈ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ បានសំរេចចំណាយរឿងរដ្ឋប្បវេណីលេខ១២៨៤ចេញពីបញ្ជីក្តី។ តុលាការក្រុងភ្នំពេញបានចេញដីកាលេខ៨១៧៤ត.រ/២០០០ ចេញពីបញ្ជីក្តីតុលាការក្រុងមិនទាន់បានជំរះទេ បណ្តឹងសាទុក្ខបដិសេធតុលាការក្រុងភ្នំពេញរហូតមកដល់តុលាការកំពូលថ្ងៃនេះ ។ ហើយលោកម៉ាហ្គ្រាំង អ៊ែលណៃស គាត់ប្តឹងទាស់និងដីកា សាលាឧទ្ធរណ៍គួរតែតម្កល់ដីកា៨១៧៤តរ. បើបដិសេធលេខ៨១៧៤តរ តុលាការមិនទាន់បានជំរះផងនោះ គឺខុសពីសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។ ដូច្នេះសាលាឧទ្ធរណ៍ជំនុំជំរះខុសនីតិវិធីហើយ ខ្លួនសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍លេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ចោលជាអាសារបង់ និង ឱ្យតុលាការកំពូលបង្វិលសំណុំរឿងលេខ៤៦៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយលោកច្រឹង លឹមស្រ៊ី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣១៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់លោកច្រឹង-លឹមស្រ៊ី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ឱ្យដើមចោទ ហើយអោយដើមចោទបង់ប្រាក់ថ្លៃដីបង្គ្រប់ឱ្យចុងចម្លើយចំនួន៥៧.០០០ដុល្លាអាមេរិក ដោយផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៦ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

+តាមកិច្ចសន្យាចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៦ ប្រការ៤ និង ប្រការ៥ ចែងថា ដើមចោទត្រូវបង់ប្រាក់ថ្លៃដីឱ្យគ្រប់នៅបំណាច់ខែធ្នូ ឆ្នាំ១៩៩៦ បើមិនបានបង់ប្រាក់គ្រប់តាមកំណត់ទេ ចុងចម្លើយមានសិទ្ធិលក់ដីឱ្យអ្នកផ្សេងទៀត ។ ប៉ុន្តែទោះជាយ៉ាងណា ចុងចម្លើយពុំមានសិទ្ធិរំលាយកិច្ចសន្យាដោយខ្លួនបានឡើយ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបដិសេធដីកាដកល់រឿងទុកមួយអន្លើហើយសំរេចដល់រឿងអង្គសេចក្តីតែម្តងនោះ ពុំត្រឹមត្រូវទេ ពីព្រោះតុលាការជាន់ទី១ ពុំទាន់បានស៊ើបអង្កេត និងសំរេចដល់រឿងអង្គសេចក្តីទេ ។

-យល់ឃើញថា តំណាងដើមចោទពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

### ហេតុដូច្នេះ

### ទិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៣១៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់លោកច្រឹង លឹមស្រ៊ី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១០៧"ង" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤៦៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលដើមចោទបានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៥.០០០រៀល ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨ ខែវិច្ឆិកាឆ្នាំ២០០៤ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។